International
Labour
Organization

better factories
Cambodia

# សេចក្តីថ្លែងការណ៍របស់គណៈកម្មការប្រឹក្សាគំរោង (PAC)
# នៃគំរោង*រោងចក្រកាន់តែប្រសើរនៅកម្ពុជា* ស្តីពី
# ការចេញផ្សាយរបាយការណ៍សំយោគលើកទី ២១ របស់អង្គការពលកម្មអន្តរជាតិ (ILO)
# ស្តីពីល័ក្ខខ័ណ្ឌការងារ ក្នុងវិស័យកាត់ដេរនៅកម្ពុជា

១. នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៨ គណៈកម្មការប្រឹក្សាគំរោង របស់***គំរោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា*** នៃអង្គការពលកម្មអន្តរជាតិ បានជួបប្រជុំនៅទីក្រុងភ្នំពេញដើម្បីពិនិត្យមើល និង ផ្តល់ការយល់ព្រមទៅលើរបាយការណ៏សំយោគលើកទី ២១ របស់អង្គការពលកម្មអន្តរជាតិស្តីពីល័ក្ខខ័ណ្ឌការងារក្នុងវិស័យកាត់ដេរនៅកម្ពុជា។ គណៈកម្មការប្រឹក្សាគំរោងមានអ្នកតំណាងមកពី រាជរដ្ឋាភិបាលកម្ពុជា សមាគមរោងចក្រកាត់ដេរនៅកម្ពុជា និង សហជីពកម្ពុជា ។

២. សមាជិកគណៈកម្មការប្រឹក្សាគំរោង ស្វាគមន៏នូវការចេញផ្សាយរបាយការណ៏នេះ ដែលបង្ហាញព័ត៌មានស្តីពីល័ក្ខខ័ណ្ឌការងារ ដែលបង្កើតឡើងដោយប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងព័ត៌មានដោយស្វ័យប្រវត្តិ (IMS) របស់គំរោង ។

៣. យើងកត់សំគាល់ដោយសេចក្តីពេញចិត្តចំពោះការអនុលោមតាមច្បាប់ដែលមានកំរិតខ្ពស់ ជាពិសេសចំពោះការទូទាត់ប្រាក់ឈ្នួលដល់កម្មករពេញសិទ្ធិ បើទោះបីជាតំរូវអោយមានការកែលំអរមួយចំនួនចំពោះការទូទាត់ប្រាក់ឈ្នួលដល់កម្មករម្តងម្កាលផងដែរ ។ ជាការពិតយើងក៏ត្រូវបានជួយជំរុញផងដែរដែលថាមានសហជីពតិចតួចប៉ុណ្ណោះពាក់ពន្ធ័នឹងការរើសអើងសហជីព។

យើងកត់សំគាល់ដោយសេចក្តីសោកស្តាយ ចំពោះរាល់កូដកម្មដែលបានកត់ត្រានៅក្នុងរបាយការណ៏នេះ ព្រោះកម្មករនិយោជិតខកខានមិនបានអនុលោមតាមល័ក្ខខ័ណ្ឌច្បាប់មួយ ឬ ច្រើន ។

៤. យើងសូមបន្ត និង បង្ហាញនូវការគាំទ្ររបស់យើងចំពោះគំរោងរបស់អង្គការពលកម្មអន្តរជាតិ ហើយក៏សូមអំពាវនាវដល់ភាគីដែលពាក់ព័ន្ធ អោយបន្តការរួមចំណែកបន្ថែមទៀតក្នុងការកែលំអល័ក្ខខ័ណ្ឌការងារ អោយកាន់តែមានលក្ខណៈល្អប្រសើរនៅក្នុងវិស័យកាត់ដេរសំលៀកបំពាក់នៅកម្ពុជា ។

ភ្នំពេញ ថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ២០០៨